- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក និងតាមកម្មវិធីនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ជូនព្រឹទ្ធសភា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងធនធានទឹកនិងឧតុនិយម ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

ឯកតា: ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ២០២៥ | ឥណទានមុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | ការផ្ទេរចេញ | | | | 1.270.000 | |
| | ៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា និងចំណាយមិនបានគ្រោងទុក | | | | 1.270.000 | |
| 69 | ចំណាយមិនបានគ្រោងទុក | 1.672.599.600 | 1.536.653.430 | - | 1.270.000 | 1.535.383.430 |
| | ការផ្ទេរចូល | | | 1.270.000 | | |
| | ០៣-ព្រឹទ្ធសភា | | | 455.100 | | |
| 61 | សេវាកម្ម | 19.885.000 | 21.571.600 | 455.100 | - | 22.026.700 |
| | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | 614.900 | | |
| 61 | សេវាកម្ម | 109.368.800 | 109.898.800 | 614.900 | - | 110.513.700 |
| | ២៩-ក្រសួងធនធានទឹកនិងឧតុនិយម | | | 200.000 | | |
| 61 | សេវាកម្ម | 126.756.000 | 126.756.000 | 200.000 | - | 126.956.000 |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់៖

១)-ផ្តល់ជូនព្រឹទ្ធសភាចំនួន ៤៥៥,១លានរៀល សម្រាប់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំកំពូលនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៥។

២)-ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៦១៤,៩លានរៀល សម្រាប់ការប្រមូលទិន្នន័យបឋម ជារៀងរាល់ឆ្នាំ ពីភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសសហគ្រាស ដែលប្រតិបត្តិការនៅកម្ពុជា ដែលតម្រូវឱ្យមានការប្រើប្រាស់សេវាកម្មប្រមូលទិន្នន័យជាមួយក្រុមហ៊ុនប្រមូលទិន្នន័យនៅប្រទេសកម្ពុជា ដែលទទួលបានទិន្នន័យស្តីពីការចាប់យកឌីជីថលរបស់ធុរកិច្ច។

៣)-ផ្តល់ជូនក្រសួងធនធានទឹកនិងឧតុនិយមចំនួន ២០០លានរៀល សម្រាប់រៀបចំពិធីសន្និបាតបូកសរុបលទ្ធផលការងារក្រសួងធនធានទឹកនិងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរ

ទន្លេសាប ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ នៅសណ្ឋាគារ សុខា ភ្នំពេញ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក និងតាមកម្មវិធីនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាចំនួន ៤ ៩៩២ ២០០ ០០០រៀល (បួនប៊ីលានប្រាំបីរយកៅសិបពីរលានពីររយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) មកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងពាណិជ្ជកម្ម សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។



ៗ

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយជំហានទី២ ឆ្នាំ២០២៥ ដើម្បីចូលរួមពិព័រណ៍ពិភពលោក២០២៥ អូសាកា កាន់សៃ ប្រទេសជប៉ុន។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើតខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការធ្វើអនុប្បយោគ និងការផ្ទេរសិទ្ធិកាន់កាប់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



៥

**សម្រេច**

**មាត្រា១.-**

ត្រូវបានធ្វើអនុប្បយោគផ្ទៃដីមួយកន្លែងទំហំ ១ ៨០០ (មួយពាន់ ប្រាំបីរយ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិភ្នំកុយ ឃុំសាលាក្រៅ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងផ្ទេរសិទ្ធិកាន់កាប់ជូនឈ្មោះ យឿម ភឿន ដើម្បីគ្រប់គ្រង និងប្រើប្រាស់។

**មាត្រា២.-**

ត្រូវបានអនុញ្ញាតឱ្យមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន លុបទំហំដី ដូចមានចែងក្នុងមាត្រា ១ ខាងលើ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើតខែ ចេត្រ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការធ្វើអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានធ្វើអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទីតាំងដីដែលមានទំហំ ៦៣ ៩៤៨ (ហុកសិបបីពាន់ ប្រាំបួនរយសែសិបប្រាំបី) ម៉ែត្រក្រឡា ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលជាកម្មសិទ្ធិរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ មកជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកំណត់ទីតាំងនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤២៧ (បួនរយម្ភៃប្រាំពីរ) ហិកតា ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាដីឯកជនរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលនិយាមកាមដីដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤២៧ (បួនរយម្ភៃប្រាំពីរ) ហិកតា ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាដីឯកជនរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីពីការកែសម្រួលនិយាមកាមដីដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤០៧ (បួនរយប្រាំពីរ) ហិកតា ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាដីឯកជនរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ១០០ (មួយរយ) ហិកតា ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាដីឯកជនរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុងកំពង់សោម នៃខេត្តព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១ .—**

ត្រូវបានកំណត់ទីតាំងនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (International Financial Center of Cambodia (IFCC)) មានទីតាំងស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានចែងក្នុងអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩, អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០, អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០, អនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពទៅជា ភូមិអុង សង្កាត់រាម ក្រុងកំពង់សោម ខេត្តព្រះសីហនុ ស្របតាមអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុងកំពង់សោម នៃខេត្តព្រះសីហនុ។

**មាត្រា២ .—**

ផ្ទៃដីសម្រាប់ធ្វើការអភិវឌ្ឍមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ដូចមានកំណត់ទីតាំងក្នុងមាត្រា១ ដែលមានទំហំ ៩៣៤ (ប្រាំបួនរយសាមសិបបួន) ហិកតា ត្រូវបានកំណត់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ៧ ដែលមានលេខសម្គាល់ រួមមាន៖ ១៨០២០៨០១-០០៥២, ១៨០២០៨០១-០០៥៣, ១៨០២០៨០១-០០៥៤, ១៨០២០៨០១-០០៥៥, ១៨០២០៨០១-០០៥៦, ១៨០២០៨០១-០០៥៧ និង ១៨០២០៨០១-០០៦៩។



ម

**មាត្រា៣ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៥៨ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតកំពង់ផែទេសចរណ៍អន្តរជាតិកំពត**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៤/០០២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសន្តិសុខនាវានិងសន្តិសុខបបនីយកណ្ឌផែ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដែលសរសេរជាអក្សរកាត់ថា **ក.ទ.ក**. និងមានឈ្មោះជាភាសាអង់គ្លេសថា Kampot International Tourism Port ដែលមានទីតាំងស្ថិតនៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត ដើម្បីបម្រើសេវាឱ្យនាវាដឹកអ្នកដំណើរដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ជាមួយប្រទេសជិតខាង និងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា២ .-**

កំពង់ផែទេសចរណ៍អន្តរជាតិកំពតជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៣ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ជាអង្គគ្រប់គ្រងកំពង់ផែនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត។

**មាត្រា៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូនអាចប្រគល់កំពង់ផែទេសចរណ៍អន្តរជាតិកំពតទៅឱ្យក្រុមហ៊ុនឯកជនធ្វើជាប្រតិបត្តិករកំពង់ផែដើម្បីធ្វើប្រតិបត្តិការនិងថែទាំតាមរយៈការរៀបចំឱ្យមានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនឯកជននោះ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវរៀបចំយន្តការសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តសិទ្ធិនិងកាតព្វកិច្ចដែលបានបញ្ញត្តនៅក្នុងកិច្ចព្រមព្រៀង ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

**មាត្រា៥ .-**

ប្រតិបត្តិករកំពង់ផែនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ត្រូវអនុវត្តសិទ្ធិនិងកាតព្វកិច្ចដែលបានបញ្ញត្តនៅក្នុងកិច្ចព្រមព្រៀង ដូចមានចែងនៅក្នុងកថាខណ្ឌទី១ មាត្រា៤នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការកំណត់ដែនកំពង់ផែ

**មាត្រា៦ .-**

កំពង់ផែទេសចរណ៍អន្តរជាតិកំពតមានដែនទឹកនិងដីគោក។

ដែនទឹកមានទំហំ២៧៩,៩៨៥៧(ពីររយចិតសិបប្រាំបួនក្បៀសប្រាំបួនពាន់ប្រាំបីរយហាសិបប្រាំពីរ) ហិកតា និងដីគោកមានទំហំ៣,៧៧៤២(បីក្បៀសប្រាំពីរពាន់ប្រាំពីររយសែសិបពីរ)ហិកតា មានព្រំដែននិងនិយាមកានៅក្នុងគម្រោងប្លង់រួមនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ដែនទឹកនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពតដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៦នៃអនុក្រឹត្យនេះ ត្រូវទុកជាកម្មវត្ថុសម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ដោយអង្គគ្រប់គ្រងកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដែលរួមមាន ប្រឡាយនាវាចរណ៍ សញ្ញាជំនួយនាវាចរណ៍ អាងបត់នាវា និងបបនីយកណ្ឌផ្សេងទៀត ដើម្បីធានាដល់កិច្ចការពារសុវត្ថិភាព សន្តិសុខ និងបរិស្ថាន នៅក្នុងដែនទឹកនៃកំពង់ផែនេះ។

## ជំពូកទី៤
## ឋបនីយកណ្ឌផែ

**មាត្រា៨ .-**

ឋបនីយកណ្ឌសំខាន់ៗក្នុងដែនទឹកនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត មានដូចខាងក្រោម៖

- ប្រឡាយនាវាចរណ៍ មានទទឹងពី១៦០(មួយរយហុកសិប)ម៉ែត្រ ដល់៣៤០(បីរយសែសិប)ម៉ែត្រ និងបណ្ដោយ១៥(ដប់ប្រាំ)គីឡូម៉ែត្រ ដោយគិតចាប់ពីនិយាមកាលេខសេសពីលេខ១ដល់លេខ៦៧ និងនិយាមកាលេខគូពីលេខ២ដល់លេខ៧២
- អាងបត់នាវា ដែលជាផ្នែកមួយនៃប្រឡាយនាវាចរណ៍ មានអង្កត់ផ្ចិតប្រវែង២៥០(ពីររយហាសិប)ម៉ែត្រ ដែលមានចំណុចផ្ចិតស្ថិតនៅលើចំណុចនិយាមកា X 414198, Y 1168321
- សញ្ញាជំនួយនាវាចរណ៍ ប្រព័ន្ធ និងឋបនីយកណ្ឌផ្សេងទៀត ដែលចាំបាច់ធានាដល់សុវត្ថិភាព សន្តិសុខ និងបរិស្ថាន សម្រាប់នាវាដែលធ្វើនាវាចរណ៍ឆ្លងកាត់ប្រឡាយនាវាចរណ៍នៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត។

**មាត្រា៩ .-**

ឋបនីយកណ្ឌសំខាន់ៗនៅលើដីគោកនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ចែកចេញជាពីរផ្នែក ដូចខាងក្រោម៖

ផ្នែកទី១ ជាទីបរិវេណស្នាក់ការមេ រួមមានអគាររដ្ឋបាល អគារបច្ចេកទេស បន្ទប់ទឹកសាធារណៈ ឋបនីយកណ្ឌទទួលសំរាម អាងស្តុកទឹកក្រោមដី ចំណតរថយន្ត សួនច្បារ ស្រះទឹក ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹកស្អាត ស្ថានីយ៍និងប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធពន្លត់អគ្គីភ័យ និងរបងព័ទ្ធជុំវិញដែលមានច្រកចូល ច្រកចេញ ច្រកចូលចេញ និងប៉ុស្តិ៍យាម ដើម្បីធានាដល់ប្រតិបត្តិការកំពង់ផែ ប្រកបដោយសន្តិសុខ សុវត្ថិភាព និងបរិស្ថាន និងមានទំហំ៣,៣៨២៦(បីក្បៀសបីពាន់ប្រាំបីរយម្ភៃប្រាំមួយ)ហិកតា ស្ថិតនៅលើនិយាមកាពីលេខ១ដល់លេខ៦។

ផ្នែកទី២ ជាចំណតនាវា ស្ថិតនៅលើមាត់ព្រែក មានទំហំ០,៣៩១៦(សូន្យក្បៀសបីពាន់ប្រាំបួនរយដប់ប្រាំមួយ)ហិកតា និងមានប្រវែង១០៣(មួយរយបី)ម៉ែត្រ ស្ថិតនៅលើនិយាមកាពីលេខ១ដល់លេខ៦។

**មាត្រា១០ .-**

អគាររដ្ឋបាលនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ជាច្រកចូលចេញនៃអ្នកដំណើរ មានកន្លែងអ្នកដំណើររង់ចាំ ការិយាល័យធ្វើការរបស់ប្រតិបត្តិករកំពង់ផែនិងមន្ត្រីមានសមត្ថកិច្ច។

## ជំពូកទី៥
## មន្ត្រីមានសមត្ថកិច្ចប្រចាំការនៅកំពង់ផែ

**មាត្រា១១ .-**

កំពង់ផែទេសចរណ៍អន្តរជាតិកំពត ត្រូវមានមន្ត្រីមានសមត្ថកិច្ចប្រចាំការ ដែលរួមមាន មន្ត្រីចត្តាឡីស័កនៃក្រសួងសុខាភិបាល មន្ត្រីនគរបាលអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ មន្ត្រីគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមេបញ្ជាការផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីអនុវត្តច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ច្បាប់ផ្សេងទៀតនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៥

ស្តីពីការបង្កើតកំពង់ផែទេសចរណ៍អន្តរជាតិកំពត

**គម្រោងប្លង់រួមនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ប្រព័ន្ធបញ្ជរតែមួយជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៥ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖ ១.កិច្ចព្រមព្រៀងស្តីពីការបង្កើតនិងការអនុវត្តបញ្ជរតែមួយអាស៊ាន ២.ពិធីសារស្តីពីការបង្កើតនិងការអនុវត្តបញ្ជរតែមួយអាស៊ាន ៣.ពិធីសារស្តីពីក្របខណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន

- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ចរតែមួយជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ចរតែមួយជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៧០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការដាក់ឱ្យប្រើបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ចរតែមួយជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការគ្រប់គ្រងនិងកិច្ចដំណើរការប្រព័ន្ធបញ្ចរតែមួយជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការស្នើសុំនិងការផ្ដល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀត សម្រាប់ការនាំចេញ នាំចូល ឬទំនិញឆ្លងកាត់ដូចខាងក្រោម៖

- ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់
- ទំនិញស្ថិតក្នុងកាតព្វកិច្ចនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- ទំនិញស្ថិតក្នុងកាតព្វកិច្ចនៃការអនុវត្តអនុសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត
- ផលិតផលតេលសិលា និងទំនិញនៃអគារលក់ទំនិញរួចពន្ធ
- ទំនិញទទួលបានការលើកលែងពន្ធនិង/ឬអាករ របស់គម្រោងវិនិយោគ
- ទំនិញទទួលបានការលើកលែងពន្ធនិងអាកររបស់ក្រសួង ស្ថាប័ន បេសកកម្មការទូត បេសកកម្មកុងស៊ុលបរទេស និងអង្គការជាតិ/អន្តរជាតិនានា
- ទំនិញទទួលបានការលើកលែងពន្ធនិងអាករផ្សេងទៀត តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ប្រព័ន្ធបញ្ចរតែមួយជាតិ** សំដៅដល់ថ្នាលបច្ចេកវិទ្យាព័ត៌មានដែលអនុញ្ញាតឱ្យបុគ្គលដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល និងទំនិញឆ្លងកាត់អាចស្នើសុំ អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារតម្រូវផ្សេងទៀត ទៅគ្រប់ក្រសួង ស្ថាប័ន មានសមត្ថកិច្ចតែមួយលើករួមគ្នា ដើម្បីទទួលបាននូវការអនុញ្ញាត សម្រាប់យកទៅប្រើក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយ តាមប្រព័ន្ធអេឡិចត្រូនិក។

- **ប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នាឬទាក់ទងគ្នាតាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។
- **ទិន្នន័យ** សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើក្នុងមូលដ្ឋានទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក។
- **ប្រធានសក្តិ** សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅពីឆន្ទៈមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ។

**មាត្រា៥ .-**

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀតតាមប្រព័ន្ធបញ្ជរតែមួយជាតិ ដែលមានអាសយដ្ឋាន https://nsw.gov.kh សម្រាប់មុខទំនិញដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ស្របតាមមាត្រា២នៃអនុក្រឹត្យនេះ។

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវកំណត់អំពីនីតិវិធីលម្អិតបន្ថែម ពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀត តាមតម្រូវការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការនិងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការនិងផ្លាស់ប្តូរទិន្នន័យ ឯកសារ និងព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣
## ការប្រើប្រព័ន្ធបញ្ជរតែមួយជាតិ

**មាត្រា៧ .-**

បុគ្គលដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល និងទំនិញឆ្លងកាត់ អាចចូលប្រើប្រព័ន្ធបញ្ជរតែមួយជាតិ មានដូចជា៖

- មន្ត្រីដែលមានសមត្ថកិច្ចនៃក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គការ ស្ថានទូត ឬស្ថានកុងស៊ុល
- អ្នកនាំចេញនាំចូល



ៗ

- ជើងសាគយ និង
- បុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីក្រុមអនុវត្តគម្រោងបញ្ចរតែមួយជាតិ។

**មាត្រា៨ .-**

បុគ្គលដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំចុះឈ្មោះដើម្បីចូលប្រើប្រព័ន្ធបញ្ចរតែមួយជាតិ ស្របតាមបែបបទនិងនីតិវិធីដែលកំណត់ដោយក្រុមអនុវត្តគម្រោងបញ្ចរតែមួយជាតិ។

**មាត្រា៩ .-**

ក្រុមអនុវត្តគម្រោងបញ្ចរតែមួយជាតិ និងបុគ្គលដូចមានចែងក្នុងមាត្រា៧ ខាងលើត្រូវៈ

- រក្សាសុវត្ថិភាពទិន្នន័យ ព័ត៌មាន និងគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌ ការសម្ងាត់វិជ្ជាជីវៈ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និង
- ទទួលខុសត្រូវលើទិន្នន័យដែលខ្លួនបានបង្កើត កែសម្រួល ផ្លាស់ប្តូរ ឬធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធបញ្ចរតែមួយជាតិ។

**មាត្រា១០ .-**

ប្រព័ន្ធបញ្ចរតែមួយជាតិ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួង ស្ថាប័ននានា តាមការចាំបាច់ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការផ្លាស់ប្តូរទិន្នន័យឬឯកសារពាណិជ្ជកម្មក្នុងទម្រង់អេឡិចត្រូនិក។

**មាត្រា១១ .-**

ប្រព័ន្ធបញ្ចរតែមួយជាតិ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ចរតែមួយអាស៊ាន និង/ឬ ប្រព័ន្ធអេឡិចត្រូនិករបស់ប្រទេសដៃគូពាណិជ្ជកម្មនានា ដើម្បីផ្លាស់ប្តូរទិន្នន័យឬឯកសារពាណិជ្ជកម្មឆ្លងកាត់ព្រំដែនក្នុងទម្រង់អេឡិចត្រូនិកជាមួយបណ្តាប្រទេសទាំងនោះ ស្របតាមកិច្ចព្រមព្រៀងពាក់ព័ន្ធនានា ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។

## ជំពូកទី៤
## កិច្ចដំណើរការប្រព័ន្ធបញ្ចរតែមួយជាតិ

**មាត្រា១២ .-**

ការស្នើសុំអាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀតត្រូវធ្វើឡើងដោយម្ចាស់ទំនិញ ឬតំណាងដែលទទួលបានការអនុញ្ញាតឱ្យបំពេញបែបបទក្នុងនាមម្ចាស់ទំនិញដោយត្រូវផ្តល់ព័ត៌មានស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៣ .-**

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធ មានភារកិច្ចពិនិត្យនិងសម្រេចលើការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀត ដោយផ្អែកលើគោលការណ៍ហានិភ័យ ស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវពិនិត្យនិងសម្រេចក្នុងរង្វង់រយៈពេល ៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលទទួលបានការស្នើសុំនិងឯកសារគ្រប់គ្រាន់តាមការកំណត់។

ក្នុងករណីប្រធានសក្តិឬដោយសារបញ្ហាបច្ចេកទេសជាយថាហេតុ បណ្តាលឱ្យប្រព័ន្ធបញ្ជរតែមួយជាតិ ឬប្រព័ន្ធរបស់ក្រសួង ស្ថាប័ន មិនអាចដំណើរការបាន ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអាចចាត់ចែងអនុវត្តនីតិវិធីនៅក្រៅប្រព័ន្ធជាបណ្តោះអាសន្នតាមបទប្បញ្ញត្តិជាធរមាន ដោយត្រូវជូនដំណឹងមកគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ និងក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ រហូតដល់ប្រព័ន្ធដំណើរការឡើងវិញ។

**មាត្រា១៤ .-**

ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិត្រូវ៖

- គ្រប់គ្រងនិងផ្តល់គណនីប្រើប្រព័ន្ធជូនបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះស្របតាមការស្នើសុំ
- ថែទាំ រក្សាសុវត្ថិភាព និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធបញ្ជរតែមួយជាតិ និង
- សម្របសម្រួលដើម្បីពង្រីកការតភ្ជាប់ ធានានិរន្តរភាពក្នុងការងារតភ្ជាប់ និងកិច្ចដំណើរការនៃប្រព័ន្ធរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៥
## កម្រៃសេវាសាធារណៈ

**មាត្រា១៥ .-**

ការយកកម្រៃសេវាសាធារណៈសម្រាប់ការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀតតាមប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៦ .-**

រាល់ការទូទាត់កម្រៃសេវាសាធារណៈក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិក លើកលែងមានការកំណត់ដោយឡែក។

ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិត្រូវបន្តសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីឱ្យការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកប្រព្រឹត្តទៅដោយរលូន ពេញលេញ និងមានប្រសិទ្ធភាព។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៧ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចដំណើរការតាមប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវបន្តនិរន្តរភាពរបស់ខ្លួន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការដឹកនាំ**

**គម្រោងបញ្ជរតែមួយជាតិ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៧៩ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយការងារ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនបុគ្គលិកអប់រំ ចំនួន ៧១រូប នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | | | |
|---|---|---|---|
| ១- | លោកស្រី | វណ្ណ សិរីមន្តី | អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង |
| ២- | លោក | ឌុក ផាគីណា | នាយករងវិទ្យាល័យព្រះរាជបូជនីយកិច្ច ក្រុងស្ទឹងត្រែង |
| ៣- | លោក | ឯម ចាន់ធី | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |

| | | |
|---|---|---|
| ៤- លោក | អាន ចាន់ធី | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៥- លោក | ឱ សុជាតិ | នាយករងវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន អូរពងមាន់ ក្រុងស្ទឹងត្រែង |
| ៦- លោក | រឿន រឿន | នាយកវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ៧- លោកស្រី | ខុន ចន្ធី | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ៨- លោក | ម៉ោង ម៉េង | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ៩- លោក | សួន សុធារី | នាយកវិទ្យាល័យព្រះគោ ស្រុកថាឡាបរិវ៉ាត់ |
| ១០- លោក | ថោង ថៃ | គ្រូបង្រៀនអនុវិទ្យាល័យស្រែស្សី ស្រុកថាឡាបរិវ៉ាត់ |
| ១១- លោកស្រី | ធិន សុខឃុន | គ្រូបង្រៀនអនុវិទ្យាល័យថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ |
| ១២- លោក | គឹម ប៊ុនណារ៉ុន | នាយកអនុវិទ្យាល័យព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ |
| ១៣- លោក | ណែម ណុំ | នាយកវិទ្យាល័យបុរីអូរស្វាយសែនជ័យ ស្រុកបុរីអូរស្វាយសែនជ័យ |
| ១៤- លោក | សាយ សូភី | គ្រូបង្រៀនអនុវិទ្យាល័យព្រៃទទឹងសែនជ័យ ស្រុកបុរីអូរស្វាយសែនជ័យ |
| ១៥- លោកស្រី | វ៉ាន់ ណារី | នាយិកាអនុវិទ្យាល័យសែនសុខ ស្រុកសៀមបូក |
| ១៦- លោក | សៀន ចាន់ថាវី | គ្រូបង្រៀនអនុវិទ្យាល័យសៀមបូក ស្រុកសៀមបូក |
| ១៧- លោក | លឹម ពិសិដ្ឋ | នាយកអនុវិទ្យាល័យសន្តិភាព ស្រុកសៀមប៉ាង |
| ១៨- លោក | ខុន សុខែត | គ្រូបង្រៀនអនុវិទ្យាល័យសេរីវត្ត ស្រុកសៀមប៉ាង |
| ១៩- លោកស្រី | ហ៊ាង យ៉េតហួង | គ្រូបង្រៀនអនុវិទ្យាល័យសេរីវត្ត ស្រុកសៀមប៉ាង |
| ២០- លោក | ព្រឹង នូកន | នាយកវិទ្យាល័យសេសានសុវត្ថិភាព ស្រុកសេសាន |
| ២១- លោកស្រី | សា សិលា | គ្រូបង្រៀនអនុវិទ្យាល័យសេសាន ស្រុកសេសាន |
| ២២- លោក | វ៉ាន់ ចាន់ផ៍យ៉ា | គ្រូបង្រៀនវិទ្យាល័យសេសានសុវត្ថិភាព ស្រុកសេសាន។ |

ខ-មេដាយ **ប្រាក់ការងារ**

| | | |
|---|---|---|
| ១- លោកស្រី | លួន ថាវ៉ារិន | អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង |
| ២- លោក | ដែង សុគ្គៈ | ប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង |
| ៣- លោក | សុខ ឈុន | នាយករងវិទ្យាល័យព្រះរាជបូជនីយកិច្ច ក្រុងស្ទឹងត្រែង |
| ៤- លោក | សុខ ឈាន | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៥- លោកស្រី | ឡែ យុទ្ធនា | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៦- លោកស្រី | ឡុង ប៊ុនឡូម | គ្រូបង្រៀនអនុវិទ្យាល័យព្រះបាទ ក្រុងស្ទឹងត្រែង |
| ៧- លោក | លី សុខាន់ | គ្រូបង្រៀនអនុវិទ្យាល័យ ហ៊ុន សែន សាមគ្គី ក្រុងស្ទឹងត្រែង |
| ៨- លោកស្រី | យ៉ាន់ សុវិជ្ជា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ៩- លោកស្រី | ស៊ុក ជាតា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ១០- លោក | សៀន ពទ្ធា | គ្រូបង្រៀនអនុវិទ្យាល័យ ហ៊ុន សែន សាមគ្គី ក្រុងស្ទឹងត្រែង |
| ១១- លោក | ផាន់ ភាន | នាយកអនុវិទ្យាល័យស្រែឫស្សី ស្រុកថាឡាបរិវ៉ាត់ |
| ១២- លោក | វ៉ាន់ ចាន់ឡា | គ្រូបង្រៀនអនុវិទ្យាល័យទួលមាសអូរវៃ ស្រុកថាឡាបរិវ៉ាត់ |
| ១៣- លោកស្រី | យឹម សុគន្ធារី | គ្រូបង្រៀនវិទ្យាល័យព្រះគោ ស្រុកថាឡាបរិវ៉ាត់ |

| | | | |
|---|---|---|---|
| ១៤- | លោកស្រី | ឈាន កញ្ញា | គ្រូបង្រៀនអនុវិទ្យាល័យទួលត្នោតថ្មី ស្រុកថាឡាបរិវ៉ាត់ |
| ១៥- | លោក | សន សាំងតូ | គ្រូបង្រៀនអនុវិទ្យាល័យកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ |
| ១៦- | លោក | ខាំហាក់ សុវណ្ណា | គ្រូបង្រៀនអនុវិទ្យាល័យសៀមបូក ស្រុកសៀមបូក |
| ១៧- | លោកស្រី | តាន់ ស្រីផាន | គ្រូបង្រៀនអនុវិទ្យាល័យថ្មតាព្រហ្ម ស្រុកសៀមបូក |
| ១៨- | លោក | ង៉េត សុមេធ | នាយកអនុវិទ្យាល័យស្រែសំបូរ ស្រុកសៀមប៉ាង |
| ១៩- | លោកស្រី | ផន ចាន់ថន | គ្រូបង្រៀនអនុវិទ្យាល័យសេរីវត្ត ស្រុកសៀមប៉ាង |
| ២០- | លោក | សែ សាម៉យ | គ្រូបង្រៀនអនុវិទ្យាល័យព្រែកមាស ស្រុកសៀមប៉ាង |
| ២១- | លោក | សឿន ប៊ុនជឿន | គ្រូបង្រៀនអនុវិទ្យាល័យភ្លុក ស្រុកសេសាន។ |

គ-មេដាយ **សំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១- | លោក | រី ប៊ុនញ៉ាន | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង |
| ២- | លោក | ស៊ុយ បូរៀប | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង |
| ៣- | លោក | សំអុល វឌ្ឍម៉ានូ | មន្ត្រី នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង |
| ៤- | លោកស្រី | សារី លីដា | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៥- | លោកស្រី | ជេត កល្យាណ | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៦- | លោកស្រី | ហុង សេងហោ | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៧- | លោកស្រី | ទី មន្នីរ័ត្ន | គ្រូបង្រៀនវិទ្យាល័យព្រះរាជបូជនិយកិច្ច ក្រុងស្ទឹងត្រែង |
| ៨- | លោកស្រី | នួន រជន្នី | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ៩- | លោក | សែម ចិន្តា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ១០- | លោក | ច័ន្ទ ស៊ីថុន | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ១១- | លោកស្រី | សុខ មករា | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ១២- | លោក | ស្វាយ ចាន់សុធី | គ្រូបង្រៀនវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ១៣- | លោកស្រី | តូប សូភា | គ្រូបង្រៀនអនុវិទ្យាល័យព្រះបាទ ក្រុងស្ទឹងត្រែង |
| ១៤- | លោក | កុត តាង | គ្រូបង្រៀនវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន អូរពងមាន់ ក្រុងស្ទឹងត្រែង |
| ១៥- | លោក | អេង ចាន់ដែន | គ្រូបង្រៀនវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន អូរពងមាន់ ក្រុងស្ទឹងត្រែង |
| ១៦- | លោកស្រី | លី សុវណ្ណដា | នាយិកាអនុវិទ្យាល័យចំការលើ ស្រុកថាឡាបរិវ៉ាត់ |
| ១៧- | លោក | គីម សុផាណាល់ | គ្រូបង្រៀនអនុវិទ្យាល័យថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ |
| ១៨- | លោកស្រី | ផៃ សុធារី | គ្រូបង្រៀនអនុវិទ្យាល័យអន្លង់កេ ស្រុកថាឡាបរិវ៉ាត់ |
| ១៩- | លោក | ទឹម ហៃ | គ្រូបង្រៀនអនុវិទ្យាល័យស្រែស្បើ ស្រុកថាឡាបរិវ៉ាត់ |
| ២០- | លោក | ហ៊ិន សុណា | គ្រូបង្រៀនអនុវិទ្យាល័យទួលមាសអូររ៉ៃ ស្រុកថាឡាបរិវ៉ាត់ |
| ២១- | លោកស្រី | សៅ ស្រីទូច | គ្រូបង្រៀនអនុវិទ្យាល័យអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ |
| ២២- | លោកស្រី | យូ ចាន់ពិសី | គ្រូបង្រៀនអនុវិទ្យាល័យថ្មតាព្រហ្ម ស្រុកសៀមបូក |
| ២៣- | លោកស្រី | ថា ពៅយ៉ា | គ្រូបង្រៀនអនុវិទ្យាល័យសៀមបូក ស្រុកសៀមបូក |
| ២៤- | លោក | លឿង ភត្រា | គ្រូបង្រៀនអនុវិទ្យាល័យថ្មតាព្រហ្ម ស្រុកសៀមបូក |
| ២៥- | លោកស្រី | វ៉ាត់ សុជា | គ្រូបង្រៀនបឋមសិក្សាស្នាកោះ ស្រុកសៀមបូក |

២៦- លោក ហ្វយ សង្ហា នាយកអនុវិទ្យាល័យព្រែកមាស ស្រុកសៀមប៉ាង

២៧- លោក ចាន់ វុធ គ្រូបង្រៀនអនុវិទ្យាល័យស្រែសំបូរ ស្រុកសៀមប៉ាង

២៨- លោក អៀត សារី គ្រូបង្រៀនវិទ្យាល័យតេជោសៀមប៉ាង ស្រុកសៀមប៉ាង។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៥

